**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខ ៧៦៣/២២ ស.ជ.ក

ថ្ងៃអង្គារ ១៣កើត ខែមិគសិរ ឆ្នាំខាល ព.ស.២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២២

# សេចក្តីជូនដំណឹង

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដែលហៅកាត់ថា **គ.ជ.ប.ជ** មានសេចក្តីរីករាយ សូមជម្រាបជូនដំណឹង ទៅគ្រប់សមាជិកក្រុមការងារអន្តរក្រសួងស្ថាប័នទាំង០៦ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណកម្មាធិការប្រឆាំងអំពើជួញដូរមនុស្ស រាជធានី/ខេត្ត (គ.រ.ប.ជ/គ.ខ.ប.ជ) មេត្តាជ្រាបថា៖ ទិវាជាតិប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០២២ នេះ ត្រូវបានប្រារព្ធធ្វើនៅថ្នាក់ជាតិ នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ នៅសាលមហោស្រព និងពិព័រណ៍កោះពេជ្រ ដោយមានការជួបជុំពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃរាជរដ្ឋាភិបាល ព្រឹទ្ធសភា រដ្ឋសភា មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ អាជ្ញាធរថ្នាក់ក្រោមជាតិ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត កុងស៊ុល និងតំណាងប្រចាំនៅកម្ពុជា ប្រធាន ឬតំណាងអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល តំណាងគ្រប់និកាយសាសនា សាស្ត្រាចារ្យ សិស្ស និស្សិត បញ្ញវ័ន្ត និងវិស័យឯកជន ប្រមាណជាង ៣០០០ អង្គ/នាក់ ។

ការប្រារព្ធកម្មវិធីនេះ គឺក្នុងគោលបំណង (១)បង្ហាញនូវស្មារតីសាមគ្គីភាព និងការយកចិត្តទុកដាក់ចំពោះការងារប្រឆាំងការជួញដូរមនុស្ស និងទាសភាពសម័យទំនើប និងការការពារសិទ្ធិមនុស្សនៅកម្ពុជា (២)ជាការបំផុសការយល់ដឹងយ៉ាងទូលំទូលាយអំពីព្រឹត្តិការណ៍ ស្ថានភាព និងនិន្នាការនៃអំពើជួញដូរមនុស្ស (៣)ធ្វើការផ្សព្វផ្សាយអំពីកិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូពាក់ព័ន្ធជាតិ អន្តរជាតិនានា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីសុវត្ថិភាព និងការអភិវឌ្ឍន៍ជាតិ ។

ដើម្បីក្លាយជាយុទ្ធនាការអប់រំផ្សព្វផ្សាយឲ្យបានទូលំទូលាយ ក្នុងនាមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សូមលើកទឹកចិត្ត ដល់គ្រប់គណៈកម្មាធិការ រាជធានី-ខេត្ត (គ.រ.ប.ជ/គ.ខ.ប.ជ) បន្តកិច្ចសហការជាមួយវិស័យពាក់ព័ន្ធ និងដៃគូជាតិ អន្តរជាតិ ឃុំ សង្កាត់ និងសាលារៀន ចាត់តាំងការរៀបចំផ្សព្វផ្សាយ តាមរូបភាពផ្សេងៗ នូវសារទាំងឡាយ នៃទិវា ១២ធ្នូ ប្រឆាំងការជួញដូរមនុស្ស ក្រោមប្រធានបទ៖ **«រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ ប្រកបដោយចីរភាព»** សម្រាប់ជាការពញ្ញាក់ស្មារតី ឲ្យប្រជាពលរដ្ឋទាំងអស់យល់ដឹងអំពី អំពើជួញដូរមនុស្ស និងចូលរួមបង្ការទប់ស្កាត់ និងការពារខ្លួនពីអំពើជួញដូរមនុស្ស ។

នេះជាការរួមចំណែកដ៏ធំធេងក្នុងការលើកកម្ពស់ សន្តិសុខ សុវត្ថិភាពសង្គម និងសន្តិភាពជាតិ ឲ្យមានស្ថេរភាព ដើម្បីធ្វើជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៍ជាតិគ្រប់វិស័យ ស្របតាមគោលដៅអភិវឌ្ឍន៍ជាតិ ប្រកបដោយចីរភាព តាមការគ្រោងទុក ។

**ជ. ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**
**អនុប្រធានអចិន្ត្រៃយ៍**

**ជួ ប៊ុនអេង**